**សម្តេចពិជ័យសេនា ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សាររំលែកមរណទុក្ខ

**ផ្ញើជូន**

**លោកជំទាវ មាឃ ឡាញ់ នៃ ប៉េណា**

លោកជំទាវ ជាទីគោរពរាប់អានដ៏ជ្រាលជ្រៅបំផុត

ភរិយាខ្ញុំ និងរូបខ្ញុំ ព្រមទាំងក្រុមគ្រួសារ សូមសម្តែងនូវសេចក្តីសោកស្តាយក្តុកក្តួលក្រៀមក្រំបំផុត ដោយទទួលដំណឹងថា **ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា** ដែលជាស្វាមីដ៏ឧត្តុងឧត្តម របស់**លោកជំទាវ** ទទួលមរណភាពនៅថ្ងៃសៅរ៍ ៥រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង១៣:០០នាទី ក្នុងជន្មាយុ៧៤ឆ្នាំ ដោយរោគាពាធ ។

មរណភាពរបស់**ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា** គឺជាការបាត់បង់ស្វាមី ឪពុក និងជីតា ជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅ និងប្រកបដោយព្រហ្មវិហារធម៌របស់លោកជំទាវ និងក្រុមគ្រួសារ និងជាការបាត់បង់កុលបុត្រខ្មែរដ៏ឆ្នើមមួយរូប ពោរពេញដោយឆន្ទៈមនសិការ ក្នុងការបម្រើបុព្វហេតុ **ជាតិ សាសនា ព្រះមហាក្សត្រ** គ្រប់កាលៈទេសៈ ។

ក្នុងឱកាសមានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមរំលែកទុក្ខនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ជាមួយគ្នានេះដែរ ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងឲ្យដួងវិញ្ញាណក្ខន្ធ**ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា** សូមឆាប់បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **លោកជំទាវ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ។

*ថ្ងៃសៅរ៍ ៥រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨

**ទៀ បាញ់**